

NAGAWORLD®
金界

**សម្រាប់ចុះផ្សាយបន្ទាន់ ៖**
១០ ធ្នូ ២០១៩

# ឈុតសម្លៀកបំពាក់តំណាងជាតិស្រស់ស្អាតជាងគេក្នុងពិភពលោក ត្រូវបានបង្ហាញ និងប្រកាសនៅណាហ្គាវើលដ៍

***រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ ៖*** ឆាកជាន់ផ្ទាល់ដីនៅណាហ្គាវើលដ៍ទី១ ត្រូវបានផ្លាស់ប្តូរទៅជាកន្លែងដើរបង្ហាញម៉ូដដ៏ធំអស្ចារ្យនៅរសៀលនេះសម្រាប់ការប្រកួតឈុតសម្លៀកបំពាក់ប្រពៃណីតំណាងជាតិដែលជាផ្នែកមួយនៃការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិឆ្នាំ២០១៩ មុនពេលការប្រកួតវគ្គផ្តាច់ព្រ័ត្រដែលនឹងត្រូវធ្វើឡើងនៅសាលមហោស្រព NABA ណាហ្គាវើលដ៍ទី២ នៅថ្ងៃទី១៤ ខែធ្នូនេះ នៅម៉ោង ៧:៣០ យប់។

បេក្ខនារីកញ្ញាឯកកំពូលសម្រស់ ៣០ រូបមកពីជុំវិញពិភពលោក បានបង្ហាញពីអត្តសញ្ញាណវប្បធម៌រៀងៗខ្លួនក្នុងឈុតសម្លៀកបំពាក់តំណាងជាតិដ៏ស្រស់ស្អាត។ បេក្ខនារីម្នាក់ៗ បានដើរបង្ហាញម៉ូដក្នុងឈុតប្រពៃណីរបស់ខ្លួនមុនពេលគណៈកម្មការជ្រើសរើសបេក្ខនារី ៥ រូបមកពីប្រទេសកម្ពុជា ម៉ាឡេស៊ី ស្រីលង្ការ ថៃ និងវៀតណាម។ ជាចុងក្រោយ កញ្ញា Marsha Sheron Martin មកពីប្រទេសស្រីលង្ការទទួលបានពានរង្វាន់ "កញ្ញាដែលស្រស់ស្អាតជាងគេក្នុងឈុតតំណាងជាតិ"។ មិនតែប៉ុណ្ណោះ ក៏មានការដើរបង្ហាញម៉ូដដ៏ប្លែក និងអស្ចារ្យរបស់ក្រុម The Privé ដែលជាក្រុមម៉ូដែលកម្ពុជាផងដែរមុនការប្រកាសលទ្ធផល។

សូមបញ្ជាក់ផងដែរថា ណាហ្គាវើលដ៍ គឺជាសណ្ឋាគារផ្លូវការនៃការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិជាលើកទីពីរបន្ទាប់ពីការរៀបចំវគ្គផ្តាច់ព្រ័ត្រនៃកម្មវិធីនេះប្រកបដោយជោគជ័យកាលពីឆ្នាំ២០១៦។ កម្មវិធីដ៏ធំនេះ នឹងត្រូវចាក់បញ្ចាំងទៅកាន់ ៨០ ប្រទេសទូទាំងពិភពលោក។ បេក្ខនារី ១ នាក់ នឹងត្រូវគ្រងមកុដជាកញ្ញាឯកទេសចរណ៍អន្តរជាតិប្រចាំឆ្នាំ២០១៩ ខណៈបេក្ខនារីលេខពីរ ៤ រូប នឹងជាប់ក្នុងប្រភេទពានរង្វាន់កញ្ញាដែល "ស្រស់ស្អាតជាងគេក្នុងឈុតប្រពៃណី" "មានទេពកោសល្យជាងគេ" "ប្រជាប្រិយជាងគេ" និង "ថតរូបស្អាតជាងគេ"។ ដើម្បីឈ្នះសំបុត្រឥតគិតថ្លៃដើម្បីមកទស្សនាការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិវគ្គផ្តាច់ព្រ័ត្រឆ្នាំ២០១៩ សូមតាមដានទំព័រហ្វេសប៊ុករបស់ណាហ្គាវើលដ៍ និងសាលមហោស្រព NABA ។

###

**អំពីការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិ ៖**

**NAGAWORLD LIMITED**
NagaWorld, Samdech Techo, Hun Sen Park, Phnom Penh, 120101, P.O. Box 1099 Phnom Penh, Kingdom of Cambodia
Tel No.: (855) 23 228822    Fax No.: (855) 23 225888
Website: www.nagaworld.com    Email: enquiries@nagaworld.com



ការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិវគ្គផ្តាច់ព្រ័ត្រ បានចាប់កំណើតឡើងក្នុងខែធ្នូ ឆ្នាំ២០០៧ និងបង្កើតឡើងដោយសហគ្រិនជនជាតិម៉ាឡេស៊ីលោក Tan Sri Datuk Danny Ooi ដោយមានគោលបំណងជួយបង្កើន និងអភិវឌ្ឍជំនាញរបស់សុភាពនារីឲ្យកាន់តែប្រសើរឡើង។ ការប្រកួតកញ្ញាឯកទេសចរណ៍អន្តរជាតិវគ្គផ្តាច់ព្រ័ត្រប្រចាំឆ្នាំដែលរៀបចំដោយក្រុមហ៊ុន D'Touch International នេះតែងតែធ្វើឡើងក្នុងទីក្រុងកូឡាឡាំពួររៀងរាល់ឆ្នាំលើកលែងឆ្នាំ២០១៦ ដែលត្រូវបានរៀបចំឡើងនៅណាហ្គាវើលដ៍ រាជធានីភ្នំពេញ។

**អំពីណាហ្គាវើលដ៍ ៖**

ជាមួយការពង្រីកបន្ថែមថ្មីចុងក្រោយ ណាហ្គាវើលដ៍ មានបន្ទប់ប្រភេទស្វ៊ីត និងដឺលុច្ស ១.៦៥៨ បន្ទប់ ភោជនីយដ្ឋាន បានីយដ្ឋាន និងក្លឹបកម្សាន្តជាង ២០ កន្លែង មណ្ឌលស្ប៉ាប្រណីត ២ សាលមហោស្រព NABA ដែលមាន ២.០០០ កៅអីនៅណាហ្គាវើលដ៍ទី២ ផ្សារទំនិញរួចពន្ធប្រតិបត្តិការដោយក្រុមហ៊ុន China Duty Free Group ដែលជាផ្សារទំនើបក្រោមដីទីមួយក្នុងប្រទេសកម្ពុជា ដែលមានលក់ទំនិញម៉ាកអន្តរជាតិល្បីៗ សេវាកម្សាន្តសម្បូរបែប និងសាលដ៏ធំសម្រាប់រៀបចំកម្មវិធីកម្សាន្ត ឬការប្រជុំផ្សេងៗ។

សម្រាប់សំណួរទាក់ទងនឹងការផ្សព្វផ្សាយ ឬរូបភាព សូមទាក់ទងមកកាន់ ៖



| | |
|---|---|
| Ms. Melanie Loong<br>Senior Marketing Communications Manager<br>Tel: (+855) 10 737 684<br>Email: melanieloong@nagaworld.com | កញ្ញា ភោគ សូលីនដា<br>Brand Executive, Marketing Communications<br>Tel: (+855) 15 61 88 86<br>Email: phouksolinda@nagaworld.com |